# សេចក្តីសង្ខេបស្តីពីគោលនយោបាយការប្រាក់របស់ស្ថាប័ន GCCF
## ថ្ងៃទី5 ខែមេសាឆ្នាំ2011

1. OPAតម្រូវអោយការប្រាក់ត្រូវតែបង់ "ការចាប់ផ្តើមនៅថ្ងៃទី30 បន្តរហូតដល់ថ្ងៃដែលការទាមទារត្រូវបានគេបង្ហាញទៅភាគីដែលត្រូវទទួលខុសត្រូវនិងបញ្ចប់នៅថ្ងៃដែលការទាមទារត្រូវបានគេបង់ប្រាក់អោយ។[1] តម្រូវការដែលការទាមទារត្រូវបានគេបង្ហាញជាលើកទីមួយទៅកាន់ភាគីដែលត្រូវទទួលខុសត្រូវគឺជាទូទៅត្រូវបានគេសំដៅជាតម្រូវការត្រូវ "បង្ហាញដល់" OPA។

2. ករណីជាច្រើនដែលបកស្រាយពាក្យ "បានបង្ហាញ" បានសន្និដ្ឋានថាត្រូវដាក់ការប្តឹងទាមទារសំណង អ្នកទាមទារសំណងត្រូវតែផ្តល់ព័ត៌មានដែលគ្រប់គ្រាន់ដើម្បីធ្វើអោយភាគីដែលត្រូវទទួលខុសត្រូវធ្វើការផ្តល់ដោយមានព័ត៌មានគ្រប់គ្រាន់និងភ្ជាប់ទៅក្នុងការចរចារប្រកបដោយអត្ថន័យ។ ដោយសារតែបទដ្ឋាននេះជាគុណវិស័យ និងមិនផ្តល់ជាខ្សែបន្ទាត់ដែលអាចអនុវត្តបានតាមបែបរដ្ឋបាលនៅក្នុងលក្ខណៈឯកភាពគ្នាដែលនឹងផ្តល់អ្នកទាមទារសំណងធ្វើការលុបចោលសេចក្តីជូនដំណឹងនៃកាលបរិច្ឆេទដែលការប្រាក់កើនឡើង ស្ថាប័ន GCCF បានកំណត់ថាវានឹងគណនា និងទូទាត់ប្រាក់សំណងសម្រាប់ការប្តឹងទាមទារទាំងអស់ (EAP ចុងក្រោយ និងបណ្តោះអាសន្ន) សម្រាប់ការខូចខាតនាពេលអតីតកាលបានដាក់ទៅស្ថាប័ន GCCF ក្រោម OPA [2] ពីថ្ងៃទី30 បន្ទាប់ពីការទាមទារត្រូវបានគេដាក់ "ផ្ញើ" រហូតដល់ថ្ងៃដែលការទាមទារត្រូវបានគេ "ទូទាត់ប្រាក់សំណង"។ ការកំណត់នេះផ្អែកទៅលើការគិតពិចារណាផ្នែករដ្ឋបាលនិងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ស្ថាប័ន GCCF នៅពេលដែលការទាមទារត្រូវបានបង្ហាញតាមផ្លូវច្បាប់ក្រោម OPA។

3. ស្ថាប័ន GCCF នឹងត្រូវអោយមានការប្តឹងទាមទារសំណង "បានផ្ញើទៅ" ក្នុងគោលបំណងនៃការគណនាការប្រាក់នៅថ្ងៃដែលការដាក់បណ្តឹងបានទទួលដោយស្ថាប័ន GCCF ឬក្រុមហ៊ុនប្រេងប៊ីភី BP ***មិនគិតបញ្ចូល*** ស្ថាប័ន GCCF ទុកដោយការប្រុងប្រយ័ត្ន នៅក្នុងករណីមានកំណត់ ដែលចាំបាច់ជាប្រយោជន៍នៃយុត្តិធម៌ ការគិតថាការទាមទារសំណង "បានដាក់ពាក្យ" សម្រាប់ជាប្រយោជន៍នៃការគណនាអត្រាការប្រាក់នៅថ្ងៃក្រោយ *ឧទាហរណ៍*។ ដែលពាក្យបណ្តឹងត្រូវបានដាក់ទៅដោយមិនមានឯកសារគាំទ្រគ្រប់គ្រាន់ដែលធ្វើអោយស្ថាប័ន GCCF មិនអាចត្រួតពិនិត្យការប្តឹងទាមទារសំណង។[3]

4. ស្ថាប័ន GCCF នឹងតម្រូវអោយការប្តឹងទាមទារត្រូវបានគេបង់ប្រាក់នៅថ្ងៃដែលមូលប្បទានប័ត្រឬការផ្ទេរតាមប្រព័ន្ធធនាគារបានផ្ញើទៅអោយអ្នកទាមទារសំណង។ នៅពេលដែលមូលប្បទានប័ត្រ ឬការផ្ទេរតាមប្រព័ន្ធធនាគារត្រូវតែធ្វើសារជាថ្មី ស្ថាប័ន GCCF នឹងតម្រូវអោយការប្តឹងទាមទារសំណងត្រូវបានគេបង់ប្រាក់នៅថ្ងៃដែលមូលប្បទានប័ត្រដែលបានចេញសារជាថ្មីឬផ្ទេរតាមប្រព័ន្ធធនាគារ***មិនគិតបញ្ចូល***ការដែលស្ថាប័ន GCCF កំណត់តម្រូវអោយការប្តឹងទាមទារត្រូវបានគេបង់ប្រាក់នៅថ្ងៃចេញប្រកាសណីយប័ត្រដើមដោយសារ (a) មូលហេតុសម្រាប់ការប្រកាសនីយប័ត្រសាជាថ្មីគឺជាកំហុសរបស់អ្នកប្តឹងទាមទារ *និង* (b) ការបង់ការប្រាក់បន្ថែមពីថ្ងៃនៃការប្រកាសនីយប័ត្រដល់ថ្ងៃការចេញប្រកាសនីយប័ត្រសារជាថ្មីដោយតុលាការ។

---

1 *សូមមើល* 33 U.S.C. §§ 2705(a) (គោលការណ៍ទូទៅដែល តម្រូវអោយភាគីដែលទទួលខុស ត្រូវត្រូវបង់ថ្លៃការប្រាក់) និង 2705 (b) ("រយៈពេលដែលការប្រាក់ត្រូវបង់គឺចាប់ផ្តើមនៅថ្ងៃទី30 រហូតដល់ថ្ងៃដែល ការទាមទារត្រូវបានគេបង្ហាញទៅភាគីដែលត្រូវទទួលខុសត្រូវ ឬអ្នកធានា និងត្រូវបានបញ្ចប់នៅថ្ងៃដែល ការទាមទារត្រូវបានគេបង់ប្រាក់។")។

2 ការទាមទារទាក់ទងនឹងការរបួសរាងកាយ និងមរណភាពៈមិនត្រូវដាក់ពាក្យទៅស្ថាប័ន GCCF ក្រោម OPA ឡើយ។ ស្របពេលជាមួយគ្នានោះដែរ ស្ថាប័ន GCCF នឹងមិនគណនា ហើយបង់ការប្រាក់ទៅលើពាក្យបណ្តឹងទាមទារសំណងទាក់ទងនឹងរបួសរាងកាយ ឬមរណភាពៈឡើយ។

3 សូមមើល 33 U.S.C. § 2705(b)(3) ("ប្រសិនបើពេលណាមួយដែលអ្នកទាមទារសំណងមិនត្រូវបានគេបង់ប្រាក់អោយដោយមូលហេតុហួសពីការគ្រប់គ្រងរបស់ភាគីដែលត្រូវទទួលខុសត្រូវ ឬដោយវាមិនត្រូវនឹងគោលការណ៍យុត្តិធម៌ មិនមានការប្រាក់ត្រូវបានគេគិតបន្ថែមក្នុងកំឡុងពេលនោះឡើយ។")។

5. អ្នកទាមទារសំណងដែលបានចុះហត្ថលេខាលើការលះបង់សិទ្ធ និងកិច្ចព្រមព្រៀងមិនប្តឹងទាមទារសំណងតាមផ្លូវច្បាប់ត្រូវទទួលនូវការទូទាត់ប្រាក់បន្ថែមរួមទាំងការបង់ការប្រាក់តាំងពីទូទាត់សំណងចុងក្រោយ ដែលគេបានទទួលនិងការលះបង់សិទ្ធិពួកគេបានផ្តល់ ត្រូវបានគេបង្កើតឡើង និងបានឆ្លុះបញ្ចាំងនូវដំណោះស្រាយពេញលេញ និងចុងក្រោយនៃការទាមទារទាំងអស់សម្រាប់ការបង់ប្រាក់រួមទាំងការប្រាក់។ ទោះបីយ៉ាងណាស្ថាប័ន GCCF បានកំណត់ការបង់ប្រាក់ដោយស្ម័គ្រចិត្តអោយអ្នកទាមទារដែលបានចុះហត្ថលេខាលើលិខិតឈប់ទាមទារសំណង និងកិច្ចព្រមព្រៀងមិនប្តឹងតវ៉ា (ដោយការបង់ប្រាក់ភ្លាមៗឬការបង់ប្រាក់ពេញលេញចុងក្រោយ)ការប្រាក់ស្តីពីការខូចខាតជាជាងចំណែកនៃការបង់ប្រាក់ពេញថ្លៃដែលបង្ហាញដោយការគណនាការខូចខាតនាពេលអនាគត។ ដោយហេតុនេះ ស្ថាប័ន GCCF នឹងគណនា និងទូទាត់ប្រាក់ដែលស្របទៅនឹងគោលនយោបាយនេះស្តីពី (a) បណ្តឹងទាមទារ EAP (b) ពាក្យបណ្តឹងទាមទារសំណងបណ្តោះអសន្ន (c) បណ្តឹងទាមទារសំណងចុងក្រោយឆាប់រហ័ស និង (d) ផ្នែកនៃបណ្តឹងទាមទារសំណងចុងក្រោយដោយមានការពិនិត្យពេញលេញ ស្តីពីការបាត់បង់ក្នុងពេលអតីតកាលជាក់ស្តែង ការប្រាក់នឹងមិនត្រូវបានគេទូទាត់ទៅលើផ្នែកនៃការទូទាត់ប្រាក់ចុងក្រោយចំពោះកត្តាដែលអាចស្តារឡើងវិញនាពេលអនាគត។

6. អត្រាការប្រាក់នឹងត្រូវបានគេគណនា "ជាមធ្យមនៃអត្រាការប្រាក់ខ្ពស់បំផុតសម្រាប់ឯកសារហិរញ្ញវត្ថុនិងពាណិជ្ជកម្មរបស់ក្រុមហ៊ុននៃបក្កភាពរបស់ខ្លួនក្នុងរយៈពេល 180 ថ្ងៃ ឬការទទួលបានតិចនៅក្នុងថ្ងៃនីមួយៗរួមទាំងកំឡុងពេលដែលការប្រាក់ត្រូវតែបង់ទៅអោយអ្នកទាមទារដូចដែលបានចុះផ្សាយនៅក្នុងសារព័ត៌មានបម្រុងសហព័ន្ធ " 33 U.S.C. § 2705(b)(4)។

7. ការប្រាក់នឹងត្រូវបានគេបង់អោយពីរដងក្នុងមួយឆ្នាំគឺនៅតំណាច់ត្រីមាសទីមួយ និងនៅចុងត្រីមាសទីបួន។

8. ការបង់ការប្រាក់នឹងត្រូវបានគេធ្វើតែនៅពេលដែលការគណនាការទាមទារសំណងនីមួយៗនៃ ការបង់ការប្រាក់មានតំលៃពីប្រាំដុល្លា ឬច្រើនជាងនេះ។